**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៨៩ អនក្រ.បក**

# អនុក្រឹត្យ

**ស្តីពី**

**វិសោធនកម្មអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគ ផ្ទៃដីទំហំ ៤.០០០ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសែនមនោរម្យ និងស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤០០០ ហិកតា ស្ថិតនៅស្រុកពេជ្រាដា ស្រុកសែនមនោរម្យ និងស្រុកអូររាំង ខេត្តមណ្ឌលគិរី

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រាមួយ. –**

ត្រូវបានវិសោធនកម្មមាត្រា១នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤.០០០ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកពេជ្រាដា ស្រុកសែនមនោរម្យ និង ស្រុកអូររាំង ខេត្តមណ្ឌលគិរី ដូចខាងក្រោម :

**មាត្រា១. – ថ្មី**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៤.០០០ (បួនពាន់)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំសុខដុម ស្រុកសែនមនោរម្យ និងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ និងដំណាំផ្សេងៗ ដូចមានក្នុងផែនទី និងនិយាមកាលេខ ៨៣០អនញ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០១១ របស់សាលាខេត្តមណ្ឌលគិរី ដែលភ្ជាប់ជាមួយនឹងលិខិតលេខ៤៥៩៣/៤៤១ កសក.នផ.ផក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រាពីរ. –**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី. –**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១២

គណៈរដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា បី
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

**ផែនទីទីតាំង ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហេង ហៀង - ស៊ុច ចាន់ធូរ ត្រេនឌីង សម្រាប់ធ្វើ**
**កសិឧស្សាហកម្ម ស្ថិតនៅក្នុងឃុំសុខដុម ស្រុកសែនមនោរម្យ និងឃុំពូជ្រៃ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី**




**សញ្ញាសំគាល់**

- ចំនុចគោល
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ផ្លូវទឹក
- ផ្លូវក្រាលគ្រួសក្រហម
- ផ្លូវរទេះ
- តំបន់ការពារ ៧៩៨ ហ.ត
- ព្រំប្រទល់ដីសម្បទាន
- ដីព្រៃរក្សាទុក ៣០០ ហ.ត
- ផ្ទៃដីពាក់ព័ន្ធជាមួយប្រជាជន ៤៣៣ ហ.ត
- តំបន់ទ្រនាប់ជងអូរ ១ ៤១០ ហ.ត

គម្របព្រៃឈើឆ្នាំ២០០៦

- ព្រៃពាក់កណ្តាលស្រោង ៣០០ ហ.ត
- ព្រៃល្បោះ ៤ ១៨៦ ហ.ត
- ព្រៃរបោង១ ២២៩ ហ.ត
- ដីគ្មានគំរបព្រៃ ២៧៤ ហ.ត

ផ្ទៃដីសរុប ៤ ៩៨៩ ហិកតា

បានឃើញ និង បញ្ជូនមក
លោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
ពូជ្រៃ ថ្ងៃទី..ខែ..៥..ឆ្នាំ២០១១
កើញ_ដ្ឋា

បានឃើញ និងបញ្ជូនមក
លោកអភិបាលស្រុកមេត្តាពិនិត្យ និងសម្រេច
សុខដុម ថ្ងៃទី..ខែ..ឆ្នាំ២០១១
គី_ខុក

លេខ.០៨៧/១១
បានឃើញ និងគោរពជូន
ឯកឧត្តមអភិបាលខេត្ត សូមមេត្តាពិនិត្យ និងសម្រេច
ពេជ្រាដា ថ្ងៃទី..៦..ខែ០៥..ឆ្នាំ២០១១
នួន_សារ៉ន

លេខ.១៥៦/១១
បានឃើញ និងគោរពជូន
ឯកឧត្តមអភិបាលខេត្ត សូមមេត្តាពិនិត្យ និងសម្រេច
សែនមនោរម្យ ថ្ងៃទី..ខែ..ឆ្នាំ២០១១
ប៉េង_សម្បត្តិ

លេខ.៤០/១១
បានឃើញ និងគោរពជូន
ឯកឧត្តមអភិបាលខេត្ត សូមមេត្តាពិនិត្យ និងសម្រេច
មណ្ឌលគិរី ថ្ងៃទី..ខែ..ឆ្នាំ២០១១

លេខ...
បានឃើញ និងគោរពជូន
ឯកឧត្តមអភិបាលខេត្ត សូមមេត្តាពិនិត្យ និងសម្រេច
មណ្ឌលគិរី ថ្ងៃទី..ខែ..ឆ្នាំ២០១១
ឈឹម_ភាន

លេខ៤៣០ មនៅ
បានឃើញ និងឯកភាព
មណ្ឌលគិរី ថ្ងៃទី..ខែ..ឆ្នាំ២០១១
ស្វាយ_សំអ៊ាង